







# សូមស្វាគមន៍ការវិលត្រឡប់មកសាលាវិញ

ខ្ញុំឈ្មោះ លោក Berstein ហើយខ្ញុំជាគ្រូបង្រៀនផ្នែកបច្ចេកទេសកុំព្យូទ័ររបស់អ្នក។ ខ្ញុំរង់ចាំជួបជាមួយអ្នកទាំងអស់។

ឆ្នាំនេះ យើងនឹងចំណាយពេលជាច្រើនជាមួយគ្នា ដើម្បីរៀន គណិតវិទ្យា និងអក្សរសាស្រ្ត ដោយប្រើកម្មវិធី Study Island, Ticket to Read, និង First in Math។ ទោះជាដូច្នេះក៏ដោយ ថ្នាក់នេះនៅតែជាថ្នាក់**បច្ចេកវិទ្យា** ដូច្នេះហើយ យើងនឹងរៀនអ្វីៗទាំងនេះ នៅក្នុងឆ្នាំសិក្សានេះ៖

ប្រាំមួយខែដំបូង យើងនឹងរៀនពីសុវត្ថិភាព ក្នុងការរាវរកអ្វីៗតាមអ៊ិនធ័រណិត និង cyber-citizenship;

ពេញមួយឆ្នាំសិក្សា យើងនឹងមានសកម្មភាពបច្ចេកទេសតូចតាចនៅចន្លោះពេលត្រៀមខ្លួនដើម្បីប្រឡង។

ថ្នាក់ទី៣ ដល់ ទី៥ នឹងរៀនស្វែងយល់ពីវិធីដំណើរការរបស់អ៊ិនធ័រណិត ព្រមទាំងការប្រើកម្មវិធី Graphic Organizing (Kidspiration) និង Comic Life;

ជាបន្ថែមទៀត សិស្សថ្នាក់ទី៥ នឹងរៀនឲ្យបានស្ទាត់ជំនាញអំពីកម្មវិធី Powerpoint នៅរដូវផ្ការីកខាងមុខនេះ។

នៅពេលអ្នកមកដល់បន្ទប់កុំព្យូទ័រ ខ្ញុំចង់បានលក្ខណៈ៣យ៉ាងពីអ្នក៖

**ត្រៀមខ្លួនជាស្រេច** - ការឲ្យពិន្ទុមិនមែនយោងទៅលើតែការប្រគល់កិច្ចការដែលគ្រូដាក់ឲ្យធ្វើតែប៉ុណ្ណោះទេ ប៉ុន្តែត្រូវយោងទៅលើការត្រៀមខ្លួនជាស្រេចរបស់អ្នក មុនចូលរៀន **និង** ពីចំណេះដឹងក្នុងការកត់ត្រាមេរៀនរបស់អ្នក - នេះគឺជាផ្នែកមួយនៃបច្ចេកវិទ្យា!

**ចេះគួរសម** - អ្នកនឹងមានកិច្ចការធ្វើជាក្រុម ហើយតម្រូវឲ្យមានការផ្តល់យោបល់ទៅលើការសិក្សា**របស់អ្នក** ក៏ដូចជាការផ្តល់ឱកាសឲ្យសិស្សរួមថ្នាក់របស់អ្នកផ្តល់យោបល់ទៅលើការសិក្សារបស់ពួកគេដែរ - **នេះ**ក៏ជាផ្នែកមួយនៃបច្ចេកវិទ្យាដែរ!

**មានការចូលរួមយ៉ាងសកម្ម** - ការឲ្យពិន្ទុនឹងយោងទៅលើការចូលរួមរបស់អ្នកនៅក្នុងថ្នាក់រៀន - បើសិនជាអ្នកមិនចូលរួមទេនោះ អ្នកនឹងមិនបានទទួលពិន្ទុដែលខ្ញុំដឹងថាអ្នកមានសមត្ថភាពអាចទទួលនោះទេ!

## ថ្នាក់បច្ចេកវិទ្យា  ស្វាគមន៍!

ដើម្បីជ្រាបពីឯកសារដែលបានបកប្រែ និងព័ត៌មានបន្ថែមជាភាសាខ្មែរ សូមមើលក្នុងវិបសៃ៖ www.philasd.org/language/khmer